ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ២៩០ សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០១៣

# ប្រកាស
# ស្តីពី
# ការបង្កើតក្រុមប្រឹក្សានីតិកម្ម
# នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែមនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.**

ត្រូវបានបង្កើតក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធានានីត្យានុកូលភាព សង្គតិភាពនិងសុខដុមភាព នៃការតាក់តែងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងធានាបាននូវប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ នៃការគ្រប់គ្រងការអនុវត្តលិខិតបទដ្ឋានគតិយុត្ត ដែលជាសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងចូលរួមចំណែកដល់ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

**ប្រការ ២.**

ក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានតួនាទីនិងភារកិច្ចដូចតទៅ ÷

- ធានាសង្គតិភាពរវាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសង្គតិភាពជាមួយច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត
- ធានាភាពរលូន និងប្រសិទ្ធភាព ក្នុងការបកស្រាយ និងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ពិនិត្យនិងសម្រេចលើសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយ ក្រៅពីបទប្បញ្ញត្តិដែលត្រូវធ្វើឡើងជាប្រចាំនិងទៀងទាត់ នៅក្នុងសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ពិនិត្យនិងសម្រេចលើសេចក្តីព្រាងវិសោធនកម្មច្បាប់និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយ ក្រៅពីបទប្បញ្ញត្តិដែលត្រូវធ្វើឡើងជាប្រចាំនិងទៀងទាត់ នៅក្នុងសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ពិនិត្យ និងសម្រេចលើសំណើបកស្រាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ពិនិត្យនិងវាយតម្លៃលើប្រសិទ្ធភាពនៃការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ដែលត្រូវបានដាក់ឱ្យអនុវត្តក្នុងក្របខណ្ឌសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ពិនិត្យនិងសម្រេចលើខ្លឹមសារនៃសេចក្តីព្រាងកិច្ចសន្យាសំខាន់ៗ ដែលមានវេទយិតភាពខ្ពស់ ឬដែលមិនមែនជាកិច្ចសន្យាដែលត្រូវធ្វើឡើងក្នុងក្របខណ្ឌការងារប្រចាំថ្ងៃ នៅក្នុងសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ពិនិត្យនិងសម្រេចអំពីដំណោះស្រាយចំពោះពាក្យបណ្តឹង ឬវិវាទនានា នៅក្នុងក្របខណ្ឌនៃសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- ពិនិត្យនិងសម្រេចលើសំណើចាត់តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការការពារផលប្រយោជន៍ផ្លូវច្បាប់របស់ក្រសួង ជាមួយស្ថាប័ពាក់ព័ន្ធនានា
- ពិនិត្យ និងសម្រេចដាក់ឱ្យប្រើជាផ្លូវការនូវកម្រងអត្ថបទច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត តាមវិស័យជំនាញក្នុងសមត្ថកិច្ចនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលស្នើឡើងដោយលេខាធិការដ្ឋាន
- ពិនិត្យ និងសម្រេចដាក់ឱ្យអនុវត្តជាផ្លូវការ ក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នូវកម្រងលិខិតរដ្ឋបាលគំរូ ដែលស្នើឡើងដោយលេខាធិការដ្ឋាន
- ពិនិត្យនិងសម្រេចដាក់ឱ្យអនុវត្តជាផ្លូវការ ក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នូវកម្រងកិច្ចសន្យាគំរូ ដែលស្នើឡើងដោយលេខាធិការដ្ឋាន
- ចាត់ចែងឱ្យមានការចូលរួមពិនិត្យ និងពិភាក្សាជាមួយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ឬក្នុងកិច្ចប្រជុំអន្តរក្រសួង លើការងាររៀបចំតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ។

**ប្រការ ៣.**

ក្រុមប្រឹក្សានីតិកម្ម ត្រូវមានសមាសភាពដូចខាងក្រោម ÷

| | |
|---|---|
| - រដ្ឋមន្ត្រី នៃ កសហវ | ប្រធាន |
| - រដ្ឋលេខាធិការ ដែលជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | អនុប្រធានប្រចាំការ |
| - រដ្ឋលេខាធិការ កសហវ | អនុប្រធាន |
| - អនុរដ្ឋលេខាធិការ កសហវ | សមាជិក |
| - អគ្គលេខាធិការ កសហវ | សមាជិក |
| - អគ្គលេខាធិការរង កសហវ | សមាជិក |
| - ប្រតិភូទទួលបន្ទុកជាអគ្គនាយក/ប្រធាននាយកដ្ឋាន/ប្រធានអង្គភាព ចំណុះ កសហវ | សមាជិក |
| - ប្រធាននាយកដ្ឋានកិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | សមាជិក |
| - ប្រធាននាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| - ប្រធាននាយកដ្ឋាននីតិកម្ម កសហវ | សមាជិក និងជាប្រធានលេខាធិការដ្ឋាន។ |

**ប្រការ ៤.**

សមាជិកនៃក្រុមប្រឹក្សានីតិកម្ម ត្រូវចូលរួមប្រជុំ តាមការកោះអញ្ជើញរបស់ប្រធាន។

ក្នុងករណីប្រធានអវត្តមាន ឬមានធុរៈ អនុប្រធានប្រចាំការត្រូវកោះអញ្ជើញ និងដឹកនាំការប្រជុំជំនួស។

ប្រការ ៥.

នាយកដ្ឋាននីតិកម្មនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបំពេញមុខងារជាលេខាធិការដ្ឋាននៃក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

លេខាធិការដ្ឋាននៃក្រុមប្រឹក្សានីតិកម្ម ត្រូវបំពេញមុខងារ និងភារកិច្ចដូចខាងក្រោម ÷

- ធ្វើជាសេនាធិការបច្ចេកទេសច្បាប់ និងរដ្ឋបាលជូនក្រុមប្រឹក្សានីតិកម្ម
- រៀបចំ និងសម្របសម្រួលកិច្ចប្រជុំរបស់ក្រុមប្រឹក្សានីតិកម្ម
- ធ្វើកំណត់ហេតុ និងរៀបចំរបាយការណ៍នៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សានីតិកម្ម
- បូកសរុបរបាយការណ៍ស្តីពីការរៀបចំតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងសេចក្តីព្រាងវិសោធនកម្មពាក់ព័ន្ធ សម្រាប់ដាក់ជូនក្រុមប្រឹក្សានីតិកម្ម ពិនិត្យ និងសម្រេច
- លើកសំណើអំពីការបកស្រាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជូនក្រុមប្រឹក្សានីតិកម្ម ពិនិត្យ និងសម្រេច
- បូកសរុបរបាយការណ៍ស្តីពីការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត សម្រាប់ដាក់ជូនក្រុមប្រឹក្សានីតិកម្ម ពិនិត្យ និងវាយតម្លៃ ឬចាត់វិធានការបន្ត
- បូកសរុបរបាយការណ៍ស្តីពីខ្លឹមសារនៃសេចក្តីព្រាងកិច្ចសន្យាសំខាន់ៗ ជូនក្រុមប្រឹក្សានីតិកម្មពិនិត្យ និងសម្រេច
- លើកសំណើ និងផ្តល់អនុសាសន៍លើដំណោះស្រាយចំពោះពាក្យបណ្តឹង ឬវិវាទនានា ដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជូនក្រុមប្រឹក្សានីតិកម្ម ពិនិត្យ និងសម្រេច
- លើកសំណើចាត់តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការការពារផលប្រយោជន៍ផ្លូវច្បាប់របស់ក្រសួង ជាមួយស្ថាប័នពាក់ព័ន្ធនានា ជូនក្រុមប្រឹក្សានីតិកម្មពិនិត្យ និងសម្រេច
- សិក្សាស្រាវជ្រាវ និងចងក្រងកម្រងអត្ថបទច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត តាមវិស័យជំនាញ ក្នុងសមត្ថកិច្ចនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជូនក្រុមប្រឹក្សានីតិកម្ម ពិនិត្យនិងសម្រេច ដាក់ឱ្យប្រើជាផ្លូវការ
- សិក្សាស្រាវជ្រាវ និងចងក្រងកម្រងលិខិតរដ្ឋបាលគំរូ ដាក់ជូនក្រុមប្រឹក្សានីតិកម្ម ពិនិត្យ និងសម្រេចដាក់ឱ្យអនុវត្តជាផ្លូវការ ក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- សិក្សាស្រាវជ្រាវ និងចងក្រងកម្រងកិច្ចសន្យាគំរូ សម្រាប់ដាក់ជូនក្រុមប្រឹក្សានីតិកម្ម ពិនិត្យ និងសម្រេចដាក់ឱ្យអនុវត្តជាផ្លូវការ ក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ផ្សព្វផ្សាយកម្រងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត តាមវិស័យជំនាញ កម្រងលិខិតរដ្ឋបាលគំរូ និងកម្រងកិច្ចសន្យាគំរូ ដែលត្រូវបានសម្រេចដាក់ឱ្យប្រើឬអនុវត្ត ជាផ្លូវការដោយក្រុមប្រឹក្សានីតិកម្ម
- ចូលរួមពិនិត្យ និងពិភាក្សាជាមួយក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ឬក្នុងកិច្ចប្រជុំអន្តរក្រសួង លើការងាររៀបចំតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ តាមការចាត់តាំងរបស់ក្រុមប្រឹក្សានីតិកម្ម
- តម្កល់អត្ថបទគតិយុត្ត នៅក្នុងមជ្ឈមណ្ឌលឯកសារច្បាប់ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គ្រប់គ្រងមជ្ឈមណ្ឌលឯកសារច្បាប់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បំពេញភារកិច្ចផ្សេងទៀត តាមការចាត់តាំងរបស់ប្រធានក្រុមប្រឹក្សានីតិកម្ម។

**ប្រការ ៦.**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៧.**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសមាសភាពដូចមានចែងក្នុងប្រការ៣ ខាងលើ ត្រូវអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ឧបនាយករដ្ឋមន្ត្រី
[illegible] ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

[illegible]

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៧ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ
- រាជកិច្ច